# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសទិវាសន្តិភាពអន្តរជាតិ
## ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨

**សូមថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ**

**ជនរួមជាតិជាទីស្នេហា**

**ទិវាសន្តិភាពអន្តរជាតិ** ត្រូវបានប្រារព្ធទូទាំងពិភពលោកនៅថ្ងៃទី ២១ ខែកញ្ញា ជារៀងរាល់ឆ្នាំ បន្ទាប់ពីមានការអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៥៥ នាឆ្នាំ២០០១ ដើម្បីលុបបំបាត់អំពើហិង្សា បញ្ឈប់សង្គ្រាម ជំរុញឲ្យមានសុខសន្តិភាពក្នុងប្រទេស ក្នុងតំបន់ ក៏ដូចជាក្នុងពិភពលោកទាំងមូល។

ដោយមានការយល់ដឹងពីតម្លៃដែលពុំអាចកាត់ថ្លៃបាន និងសារៈសំខាន់នៃសន្តិភាពសម្រាប់ប្រទេសជាតិ កម្ពុជាមានសេចក្តីសោមនស្សរីករាយចូលរួមជាមួយពិភពលោកប្រារព្ធនូវ**ទិវាសន្តិភាពអន្តរជាតិ** នៅថ្ងៃទី ២១ ខែកញ្ញា នេះ ដើម្បីលើកកម្ពស់ការយល់ដឹងពីអត្ថន័យនៃសន្តិភាពឲ្យកាន់តែទូលំទូលាយ ពង្រឹងសាមគ្គីភាព ឯកភាពជាតិ បន្តជំរុញស្មារតីនិងចូលរួមដៃគ្នាជាធ្លុងមួយថែរក្សាឲ្យបានគង់វង្សនូវសុខសន្តិភាពសម្រាប់កម្ពុជាយើង ដែលជាសេចក្តីប្រាថ្នារបស់មនុស្សគ្រប់រូប និងជាមូលដ្ឋានគ្រឹះដ៏ចាំបាច់សម្រាប់ប្រទេសបោះជំហានបន្តទៅមុខលើវិថីអភិវឌ្ឍន៍និងការរីកចម្រើន។

**ជនរួមជាតិជាទីស្នេហា**

សភាពការណ៍ជុំវិញពិភពលោកនាពេលបច្ចុប្បន្ន ពុំបានធ្វើឲ្យយើងមានសុទិដ្ឋិនិយមចំពោះការសម្រេចបាននូវសន្តិភាពសម្រាប់មនុស្សជាតិនោះទេ។ ការគំរាមកំហែងចំពោះសន្តិភាពនៅតែមានភាពស្មុគស្មាញទាំងក្នុងកម្រិតសកល និងតំបន់។ ដោយឡែក ចំពោះបរិបទនៃប្រទេសកម្ពុជា ទោះបីជាយើងទទួលបានសុខសន្តិភាពពេញបរិបូរណ៍ ក្រោយការអនុវត្តគោលនយោបាយឈ្នះ-ឈ្នះ កាលពីឆ្នាំ១៩៩៨ ហើយក្តីក៏សន្តិភាពរបស់កម្ពុជានៅតែមានលក្ខណៈផុយស្រួយ ដោយសារតែការបន្តឃាឃី និងអន្តរាគមន៍ចូលកិច្ចការផ្ទៃក្នុងកម្ពុជា ឥតឈប់ឈរពីមជ្ឈដ្ឋានខាងក្រៅ។

ទោះជាមានសម្ពាធ និងការគំរាមកំហែងដាក់ទណ្ឌកម្ម ក្រោមលេសលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សយ៉ាងណាក្តី ប្រជាជន និងរាជរដ្ឋាភិបាលកម្ពុជានៅតែប្រកាន់ខ្ជាប់នូវឆន្ទៈមុតមាំក្នុងការរក្សាសន្តិភាព និងស្ថិរភាព ឲ្យខានតែបានទោះក្នុងតម្លៃណាក៏ដោយ។ យើងធ្លាប់ហែលឆ្លងរួចហើយនូវទុក្ខលំបាកវេទនាក្នុងភ្លើងសង្គ្រាមជាងបីទសវត្សរ៍ ហើយយើងក៏ធ្លាប់ហែលឆ្លងការលំបាកដោយសារការដាក់ទណ្ឌកម្មសេដ្ឋកិច្ច និងការមិនទទួលស្គាល់ពីប្រទេសមួយចំនួនចំពោះរដ្ឋាភិបាលដែលកើតចេញ

ពីចន្ទៈប្រជាជន ដែលបានរំដោះអាយុជីវិតប្រជាជនខ្មែរចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី ៧ ខែមករា ឆ្នាំ១៩៧៩។

បទពិសោធន៍ដ៏ជូរចត់ទាំងអស់នេះហើយ ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំនៃការសម្រេចចិត្តឥតងាករេរបស់ប្រជាជនខ្មែរទូទាំងប្រទេស ក្នុងការជ្រើសយកសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ ដូចដែលបានស្តែងចេញតាមរយៈលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៨ កន្លងទៅនេះ។ ការបោះឆ្នោតនេះ បានប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌ គ្មានអំពើហិង្សា គ្មានការគំរាមកំហែង និងមានការចូលរួមពីសំណាក់គ្រប់ភាគីពាក់ព័ន្ធ ពិសេសគឺ មានការចូលរួមពីសំណាក់ប្រជាពលរដ្ឋដ៏ច្រើនកុះករ រហូតដល់ទៅ ៨៣,០២% នៃពលរដ្ឋបានចុះឈ្មោះបោះឆ្នោត។ លទ្ធផលនេះ គឺជាការឆ្លុះបញ្ចាំងឱ្យឃើញនូវឆន្ទៈគាំទ្រយ៉ាងពេញទំហឹង និងដ៏មោះមុត ពីសំណាក់ប្រជាពលរដ្ឋភាគច្រើនលើសលប់ និងពីគ្រប់មជ្ឈដ្ឋាន លើកិច្ចដំណើរការប្រជាធិបតេយ្យដ៏ត្រឹមត្រូវ និងទៀងទាត់នៅក្នុងប្រទេសកម្ពុជា ក៏ដូចជាលើភាពចាំបាច់ក្នុងការបន្តកិច្ចដឹកនាំកសាងប្រទេស នៅលើមាគ៌ានៃសុខសន្តិភាព ការអភិវឌ្ឍ និងការកែទម្រង់រដ្ឋ ក្នុងគ្រប់វិស័យឆ្ពោះទៅរកវឌ្ឍនភាព និងវិបុលភាពដ៏កាន់តែរុងរឿង។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនដល់ជនរួមជាតិទាំងអស់ ដែលតែងតែផ្តល់យុត្តិធម៌ ជំនឿ និងការគាំទ្រយ៉ាងពេញទំហឹងចំពោះរាជរដ្ឋាភិបាល និងចំពោះរូបខ្ញុំផ្ទាល់ ចំពោះកិច្ចការរក្សាសុខសន្តិភាព និងការបន្តកសាង និងអភិវឌ្ឍប្រទេសជាតិយើង។

**ជនរួមជាតិជាទីស្នេហា**

"គ្មានសន្តិភាព គឺគ្មានការអភិវឌ្ឍ។ ហើយគ្មានការអភិវឌ្ឍ ក៏គ្មានសន្តិភាពស្ថិតស្ថេរដែរ។" នេះគឺជាគោលការណ៍សត្យានុម័ត ដែលពិភពលោកទាំងមូលបានទទួលស្គាល់ និងកំពុងអនុវត្តយ៉ាងយកចិត្តទុកដាក់។

សន្តិភាពដែលយើងសម្រេចបានទូទាំងផ្ទៃប្រទេសក្រោយឆ្នាំ ១៩៩៨ បានផ្តល់កាលានុវត្តភាពដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្ទេរធនធានថវិកាទាំងឡាយពីការត្រៀមធ្វើសង្គ្រាម មកប្រើប្រាស់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ក្រោមម្លប់នៃសន្តិភាពនេះហើយដែលកម្ពុជាចាប់ផ្តើមមានកម្លាំងសេដ្ឋកិច្ច ងើបផុតចេញពីឋានៈជាប្រទេសដែលមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប កាលពីឆ្នាំ ២០១៦ ។ កម្ពុជាក៏មានចក្ខុវិស័យវែងឆ្ងាយ ក្នុងការពន្លឿនពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ច ការលើកកម្ពស់សមត្ថភាព ការប្រកួតប្រជែង ការបង្កើនផលិតភាព និងតម្លៃបន្ថែមក្នុងប្រព័ន្ធខ្សែចង្វាក់តម្លៃសកល និងបង្កើនភាពធន់នឹងវិបត្តិ ដើម្បីប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។ យើងមានមោទនភាពដែលកម្ពុជាមានសន្ទុះកំណើនសេដ្ឋកិច្ចខ្ពស់រហូតដល់ជាង ៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ និងបន្តមានកំណើន ៧,១% ក្នុងឆ្នាំនេះ និងឆ្នាំបន្ទាប់។ ជាតួផ្សំនៃសន្តិភាព អត្រាកំណើនសេដ្ឋកិច្ចខ្ពស់ រួមផ្សំនឹងការដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍ជាតិដ៏ត្រឹមត្រូវក្រោមយុទ្ធសាស្ត្រចតុកោណ បានធ្វើឲ្យអត្រានៃភាពក្រីក្ររបស់ប្រជាជនខ្មែរថយចុះយ៉ាងគំហុកពី ៥៣.២% ក្នុងឆ្នាំ២០០៤ មកនៅត្រឹម ១៣.៥% ក្នុងឆ្នាំ២០១៤។

សម្រាប់រាជរដ្ឋាភិបាលអាណត្តិទី ៦ យើងនឹងនៅតែបន្តកសាង និងអភិវឌ្ឍ ដោយផ្អែកលើសមិទ្ធផលគួរជាទីមោទនកន្លងមក ដោយបន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ ក្នុងគោលដៅបម្រើនូវ

ឧត្តមប្រយោជន៍របស់ជាតិ និងឆ្លើយតបទៅនឹងសំណូមពរ និងសេចក្ដីត្រូវការរបស់ប្រជាជន។ រាជរដ្ឋាភិបាលនឹងអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវ «យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤» ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព៖ កសាងមូលដ្ឋានឆ្ពោះទៅចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០។ នៅក្នុងយុទ្ធសាស្ត្រចតុកោណនេះ វាមិនមែនជារឿងចៃដន្យទេ ដែលសន្តិភាពនៅតែជាអាទិភាពសំខាន់ទី១ ក្នុងចំណោម «អាទិភាព ៤» របស់រាជរដ្ឋាភិបាល។

**ជនរួមជាតិជាទីស្នេហា**

បើក្រឡេកមើលលើឆាកអន្តរជាតិវិញ យើងបានប្រែក្លាយបទពិសោធន៍ដ៏ល្វីងជូរចត់នៃសង្គ្រាមរបស់យើង ឲ្យទៅជាការចូលរួមចំណែកយ៉ាងសកម្មក្នុងបុព្វហេតុសន្តិភាពពិភពលោក។ យើងមានមោទនភាពក្រៃលែងចំពោះការរួមចំណែករបស់កងកំលាំងរបស់យើង ក្នុងបេសកកម្មរក្សាសន្តិភាពរបស់ អ.ស.ប. តាមរយៈការបញ្ជូនកងទ័ពចំនួន ៥.៥៧១នាក់ ចាប់ពីឆ្នាំ ២០០៦ មកទល់បច្ចុប្បន្ន ទៅប្រទេសស៊ូដង់ ស៊ូដង់ខាងត្បូង លីបង់ អាហ្វ្រិកកណ្ដាល ឆាដ ស៊ីរី ម៉ាលី និងស៊ីព្រ៍ ។ បេសកកម្មទាំងនេះជាបេសកកម្មប្រកបដោយហានិភ័យ និងគ្រោះថ្នាក់។ ទ័ពយើងក៏បានពលីជីវិត ក្នុងពេលបំពេញបេសកកម្មក្រោមឆ័ត្រអង្គការសហប្រជាជាតិ ប៉ុន្តែគ្រោះថ្នាក់ទាំងនោះពុំបានបំបាក់ឆន្ទៈបន្តរួមចំណែករបស់កម្ពុជាក្នុងការជួយសង្គ្រោះប្រទេសដទៃ ឲ្យទទួលបានសន្តិភាព និងចាកផុតពីទុក្ខវេទនានៃសង្គ្រាម និងការបំផ្លិចបំផ្លាញនោះឡើយ។

តាមរយៈស្នាដៃ និងការរួមចំណែកទាំងអស់នេះហើយ ដែលធ្វើឲ្យសហគមន៍អន្តរជាតិផ្ដល់ទំនុកចិត្តឲ្យកម្ពុជាកាន់តួនាទីសំខាន់ពីរនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ។ ទី១. គឺឋានៈជាអនុប្រធានមហាសន្និបាត អ.ស.ប.សម្រាប់ឆ្នាំ ២០១៨-២០១៩ និងទី២. គឺឋានៈជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម អ.ស.ប.សម្រាប់អាណត្តិឆ្នាំ ២០១៩។ តួនាទីទាំងនេះនឹងផ្ដល់លទ្ធភាពកាន់តែច្រើនដល់កម្ពុជា ក្នុងការចូលរួមចំណែកដល់បុព្វហេតុនៃការរក្សាសន្តិភាព និងការជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅលើពិភពលោក។

មុននឹងបញ្ចប់ ទូលព្រះបង្គំខ្ញុំសូមអំពាវនាវដល់ជនរួមជាតិទាំងអស់ បន្តចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការលើកស្ទួយសន្តិភាពជាតិ និងអន្តរជាតិ ដោយបន្តថែរក្សាសន្តិភាពដែលមានស្រាប់ពង្រឹងឯកភាពជាតិ អនុវត្តវប្បធម៌សន្ទនា គោរពច្បាប់ ដោះស្រាយបញ្ហាដោយសន្តិវិធី និងចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់រាល់ឧបាយកល និងការប៉ុនប៉ងតាមគ្រប់រូបភាពដែលមានគោលបំណងធ្វើឲ្យប្រទេសជាតិធ្លាក់ក្នុងសភាពវឹកវរ និងអស្ថិរភាព។

ខ្ញុំសូមប្រសិទ្ធពរជូនជនរួមជាតិជាទីស្នេហា សូមបានប្រកបដោយពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨

**ហ៊ុន សែន**